**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៦៥ **នាមនាមប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ **តុលាការកំពូល**

**សាលដីកា**

លេខៈ ១៩ បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥

ចុះថ្ងៃទី៣០ខែមីនាឆ្នាំ២០០៥ ដោយមានសមាសភាព ដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រម

៤- លោក យស់ សូខឿន ជាចៅក្រម

៥- លោក ម៉ុង មុន្នីចរិយា ជាចៅក្រម របាយការណ៍

**ក្រឡាបញ្ជី**

លោក សុខ ប៊ុនសង

**តំណាងមហាអយ្យការ**

ឯកឧត្តម **ឌួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៣៣"ក" ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៦៥ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

**<u>ចំពោះ:</u>** បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០២-១០-១៩៩៩ ។ ផ្តន្ទាទោសតាមមាត្រា៤១ និង ៦៣ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១-ជនជាប់ចោទឈ្មោះ សាង ណាង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ឪពុកឈ្មោះ ឃុត សាង "ស" ម្តាយឈ្មោះ ហម ខាត់ "ស" ប្តីឈ្មោះស៊ឹង ប៉េប មានកូន០២នាក់ ទោសពីមុនគ្មាន ។

២-ជនជាប់ចោទឈ្មោះ សាង នី (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ឪពុកឈ្មោះ ឃុត សាង "ស" ម្តាយឈ្មោះ ហម ខាត់ "ស" ប្តីឈ្មោះឈិន ឃុនលី មានកូន០៦នាក់ ។

៣-ជនជាប់ចោទឈ្មោះ ស៊ឹង ប៉េប (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិកោះចូរ៉ាម ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល របររកស៊ីម៉ូតូឌុប។ ឪពុកឈ្មោះ ស៊ឹង មុត "ស" ម្តាយ ឈ្មោះដេត យ៉ា ប្រពន្ធឈ្មោះ សាង ណាង មានកូន០២នាក់ ។ ទោសពីមុនគ្មាន ។

៤-ជនជាប់ចោទឈ្មោះ ទិន ឃឿន ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

៥-ជនជាប់ចោទឈ្មោះប៉េប ណាត ភេទ ស្រី អាយុ២០ឆ្នាំ ជាតិខ្មែរ មានទីលំនៅរួមភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

-មេធាវី លោក ឡាយ ស្រ៊ីវ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ព្រេស សាមាន (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

-មេធាវី លោក ស៊ឹម ស៊ីថាន

-តាមពាក្យបណ្តឹងចុះថ្ងៃទី០២-១០-១៩៩៩ វេលាម៉ោង៨ នារីសាង ណាង ទៅដេរបញ្ឆោល ជៀមដាមឱ្យនារី ព្រេស សាមាន ហៅនាង ព្រេស សាមាន ចេញមកវិញ ឮពាក្យដូច្នេះនាង ព្រេស សាមាន បានយកដើមអំពៅមួយកំណាត់ដើរចេញទៅបានបន្តិចស្រាប់តែនាង សាង ណាង ស្ទុះមកវ៉ៃនាង បាន ប្រតាយ ប្រតប់ដួលទៅដី ក៏មានឈ្មោះ អ៊ីន រស់,យ៉ត គឹមលាន់ មកជួយចាប់ចេញទៅ ។ ខាងនារី សាង ណាង មាន ឈ្មោះស៊ឹង ប៉េប,សាង នី,ប៉េប ណាត និងទិន ឃឿន មកជួយចាប់ដែរ។ រួចក៏នាងព្រេស សាមាន មកទៀត ។ ក្នុងពេលវាយនោះ ឈ្មោះ ស៊ឹង ប៉េប ប្តីនាងសាង ណាង បានមកជួយនោះ បានចាប់ហែកអាវនាង ព្រេស សាមាន បណ្តាលឱ្យដាច់ខ្សែករច្នាទីន ទម្ងន់៣ជីបាត់ រួចក៏សមត្ថកិច្ចមកដល់បានរកឃើញខ្សែករមួយ កំណាត់វិញ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការខេត្តកណ្តាល បានសំរេចថា: ចោទប្រកាន់លើឈ្មោះ នាង សាង ណាង ,ស៊ឹង ប៉េប ,សាង នី ,ទិន ឃឿន ពីបទ: បង្ករបួសស្នាមដោយ ចេតនា ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៨"វ" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០០ របស់តុលាការខេត្ត កណ្តាល ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១- ជនជាប់ចោទឈ្មោះ ទិន ឃឿន ភេទប្រុស អាយុ២២ឆ្នាំ និង នាង,ប៉េប ណាត អាយុ២១ឆ្នាំ រួចផុតពីការចោទប្រកាន់ ពីបទ: បង្ករបួសស្នាមដោយចេតនាលើនាងព្រេស សាមាន ប្រព្រឹត្ត នៅភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០២-១០-១៩៩៩ ។ បទល្មើស ព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-៩២ ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ សាង ណាង អាយុ៤០ឆ្នាំ ដាក់ពន្ធនាគាកំណត់១៥ថ្ងៃ ពីបទៈ ជេរប្រមាថ និងកំណត់១ខែ ពីបទៈបង្ករបួសស្នាមដោយចេតនា សរុប ទោសទាំងអស់ ១ខែ ១៥ថ្ងៃ ប៉ុន្តែទោសនោះ ត្រូវព្យួររយៈពេលសាកល្បង ៥ឆ្នាំ តាមកំណត់ច្បាប់ ។ ទោសព្យួរគិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

ពីបទៈ ជេរប្រមាថ និងបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០២-១០-៩៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៤១.៦៣.៦៨.៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-៩២ ។

៣-ផ្តន្ទាទោស :ជនជាប់ចោទឈ្មោះ ស៊ឹង ប៉េប ភេទប្រុស អាយុ៤៩ឆ្នាំ និងនាង សាង នី អាយុ៣៧ឆ្នាំ ដាក់ពន្ធនាគារ កំណត់១ខែ ប៉ុន្តែពេលនេះត្រូវព្យួររយៈពេលសាកល្បង ៥ឆ្នាំ តាមកំណត់ច្បាប់ ។ ទោសព្យួរ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ពីបទៈ បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០២-១០-៩៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤១. ៦៨,៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-៩២ ។

៤-បង្គាប់ឱ្យជនជាប់ចោទឈ្មោះស៊ឹង ប៉េប សងខ្សែកប្លាទីន ទម្ងន់១ជី៦ហ៊ុន៤លី ទៅឱ្យនាងព្រេស សាមាន នៅពេលសាលក្រមចូលជាស្ថាពរ ។

៥-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ ស៊ឹង ប៉េប នាងសាង ណាង និងនាង សាង នី បង់ជម្ងឺចិត្តទៅឱ្យជនរងគ្រោះ ចំនួន៥០ម៉ឺនរៀល នៅពេលសាលក្រមចូលជាស្ថាពរ ។

៦-វត្ថុតាងមានអំពៅ២កំណត់ត្រូវរឹបអូស បំផ្លាញចោល ចំណែកអាវស្រីរហែក១ ប្រគល់ឱ្យនាងព្រេស សាមាន យកទៅប្រើប្រាស់វិញ ។

សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ នាងសាង ណាង,នាងសាង នី កំបាំងមុខជនជាប់ចោទឈ្មោះស៊ឹង ប៉េប និងចំពោះមុខជនរងគ្រោះ ។ បើកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៨០ ចុះថ្ងៃទី២៣ខែមិថុនាឆ្នាំ២០០០ របស់ឈ្មោះសាង ណាង,សាង នី ស៊ឹង ប៉េប ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១៨"រ" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០០ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ បានសំរេចថា: សាលក្រមរបស់តុលាការខេត្តកណ្តាលសំរេចមកត្រឹមត្រូវ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៣៣"ក" ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៣-៦-២០០០ របស់ជនជាប់ចោទឈ្មោះសាង ណាង.សាង នី.ស៊ឹង ប៉ែប ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២-តកល់សាលក្រមលេខ ១៨ "រ" ចុះថ្ងៃទី២៨-៤-២០០០ របស់តុលាការខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះ សាង ណាង.សាង នី.ស៊ឹង ប៉ែប.ទិន ឃឿន .ប៉ែប ណាត និងដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ព្រេស សាមាន មេធាវីជនជាប់ចោទ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ បើសិទ្ធិឱ្យប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៧១ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះ សាង ណាង. សាង នី. ស៊ឹង ប៉ែប ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៣៣"ក" ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចសាលដីកាទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ របស់ឈ្មោះ សាង ណាង.សាង នី. ស៊ឹង ប៉ែប ។

-បានឃើញសារណាតប ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះព្រេស សាមាន ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា: ក្នុងរឿងនេះ ពិតជាមានភស្តុតាង និង សាក្សីគ្រប់គ្រាន់ ដែលបញ្ជាក់ថា ឈ្មោះ សាង ណាង ,សាង នី និងឈ្មោះស៊ឹង ប៉ែប បានបង្ករបួសស្នាម លើ ជនរងគ្រោះប្រាក់ដមែន ។ ដូច្នេះ សូមតម្កល់សាលដីកាព្រហ្មទណ្ឌលេខ៣៣ "ត" ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ សាង ណាង នាពេលសវនាការ ថា : នាងខ្ញុំឈ្មោះ សាង ណាង មិនប្តឹងសាទុក្ខមិនសុខចិត្ត ព្រោះនាងខ្ញុំ :

+គ្រាន់តែខ្ញុំសម្លក់សម្លឹងទៅបងថ្លៃ និងក្មួយរបស់ព្រេស សាមាន ដែលសម្លក់គ្នាទៅវិញ ទៅមក ស្រាប់តែឈ្មោះ ព្រេស សាមាន យកដើមអំពៅមកវាយខ្ញុំត្រង់ក្បាល

+ខ្ញុំទាស់គ្នានៅហ្នឹងផ្លូវសាធារណៈ

+ខ្ញុំទៅប្តឹងតែគេមិនពិនិត្យលើបណ្តឹងខ្ញុំ

+ពីផ្ទះខ្ញុំទៅផ្ទះព្រេស សាមាន ចំងាយ១៥ម ហើយពីកន្លែងកើតហេតុទៅផ្ទះព្រេស សាមាន ប្រហែល៥ ទៅ៦ម ។

+នាងខ្ញុំគ្មានបំណងទៅរករឿងគេទេ គឺនាងខ្ញុំដើរជាក្មួយស្រី ដែលនៅតូច ដើម្បីទៅមូលបារី ស្រាប់តែនាងព្រេស សាមាន យកដើមអំពៅមកវាយខ្ញុំតែម្តង ។

+ពេលវាយគ្នានោះ គឺប្រតាយប្រតប់ និងក្រញៀគ្នាទៅវិញទៅមក ហេតុអ្វីបានជាតុលាការចោទ តែខាងនាងខ្ញុំ ដោយតុលាការជឿតែ សាក្សី ខាងនាងព្រេស សាមាន សុទ្ធតែជាបងប្អូនខ្លួនគេ ។

+នាងខ្ញុំបានទៅឱ្យពេទ្យពិនិត្យ តែពេទ្យមិនពិនិត្យ និងមិនចេញលិខិតបញ្ជាក់ពីរបួសឱ្យនាងខ្ញុំទេ ពេលនោះនាងខ្ញុំទៅតុលាការ ពេលនោះអ្នកស្រីគង់ គួយ បានធ្វើកំណត់ហេតុ និងបានអានឱ្យនាងខ្ញុំស្តាប់ គឺនាងខ្ញុំមានពកក្បាល និងជាំភ្នែក ។

+ការវាយគ្នានោះខាងព្រេស សាមាន ក៏មានបងប្អូន ២ ទៅ៣នាក់ ក៏មកជួយដែរ ។

ដូច្នេះ សូមតុលាការជួយរកយុត្តិធម៌ឱ្យនាងខ្ញុំផង ។

បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ នាង សាង ទី នាពេលសវនាការ ថា : នាងខ្ញុំកំពុងចាក់អង្ករស្រាប់តែ ឮ គេស្រែកថា គេវាយបងនាងឯង ហើយពេលនោះ នាងខ្ញុំក៏ស្ទុះទៅស្រាប់តែ នាងខ្ញុំឃើញឈ្មោះព្រេស សាមាន វាយមកលើបងខ្ញុំ ខ្ញុំក៏ប្រឡេះកអាវរបស់នាង ព្រេស សាមាន ទាញចេញពីបងនាងខ្ញុំតែប៉ុណ្ណោះ គឺនាងខ្ញុំមិនបានវាយព្រេស សាមាន ទេ ។

បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ស៊ឹង ប៉េប នាពេលសវនាការ ថា :ពេលវាយគ្នានោះ ខ្ញុំកំពុងដាំបាយ ខ្ញុំមិនដឹងអ្វីទេ តែមានគេទៅប្រាប់ថា គេវាយប្រពន្ធហើយ ដោយគេនោះនិយាយខ្លាំង១ ធ្វើឱ្យខ្ញុំព្ញស្ទុះទៅមើលប្រពន្ធ ព្រោះខ្លាចងាប់ គឺខ្ញុំមិនបានវាយគេទេ ។

បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ព្រេស សាមាន នាពេលសវនាការ ថា : ឈ្មោះ សាង ណាង ចេះតែដើរជេរខ្ញុំទៅមក១ ហើយមកជេរដល់មុខផ្ទះខ្ញុំ គឺកាច់ជ្រុងផ្ទះ

+គាត់មកជេរតែម្នាក់ឯងដំបូង

+ខ្ញុំក៏បានយាដើមអំពៅ បំរុងវាយមែន តែត្រូវកូនសាង ណាង ចាប់ទាញនាងខ្ញុំទៅក្រោយវិញ គឺឈ្មោះប៉េប ណាត ។

+ខ្ញុំត្រូវបានសាង ណាង សង្កត់ពីលើ ដោយវាយនាងខ្ញុំរយះស្បែកទ្រូង និងមុខជាច្រើនកន្លែង គឺនាងខ្ញុំមិនបានវាយទៅលើសាង ណាង វិញទេ សូមតុលាការកំពូល ជួយរកយុត្តិធម៌ផង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោក ឡាយ ស្រ៊ុំ ការពារឱ្យជនជាប់ចោទ នាពេលសវនាការ ថា:

+ ក្នុងរឿងនេះ បើពិនិត្យឱ្យល្អិតល្អន់ ជារឿងជេរគ្នាទៅវិញ ទៅមក មិនមែនបង្ករឿងតែកូនក្តីខ្ញុំម្ខាងនោះទេ ព្រោះកូនក្តីខ្ញុំមានស្នាកស្នាមរបួសដូចជាជាំភ្នែក ពកក្បាល ដូចមានក្នុងកំណត់ហេតុយកចម្លើយចុះថ្ងៃទី០៥-១០-១៩៩៩ របស់តុលាការខេត្តកណ្តាលជាភស្តុតាងស្រាប់ ។

+ កូនក្តីខ្ញុំបានទៅពេទ្យឱ្យជួយពិនិត្យ តែពេទ្យមិនបានចេញលិខិតបញ្ជាក់កូនក្តីខ្ញុំទេ ព្រោះកូនក្តីខ្ញុំជាមនុស្សល្ងង់ ហើយពេលនោះក៏ពុំកគាត់មិនមានមេធាវីដែរ ។

+កូនក្ដីខ្ញុំត្រូវបានតុលាការខេត្តកណ្ដាលកាត់ដោយលំអៀង ដែលមិនបានចោទប្រកាន់ទៅភាគីខាងព្រេស សាមាន ទេ ព្រោះរឿងនេះ ខាងនាងព្រេស សាមាន ជាអ្នកបង្កហេតុមុន ដូចជានៅមានឈ្មោះព្រេស សាមាន និង អ៊ិន រស់ សុទ្ធតែអ្នកចូលរួមព្រួតវាយកូនក្ដីខ្ញុំ តែត្រូវបានតុលាការមិនធ្វើការចោទប្រកាន់ គឺកាត់ក្ដីដោយជឿតែលើសាក្សីរបស់ដើមចោទសុទ្ធតែជាបងប្អូនខ្លួន និងសំបុត្រពេទ្យតែប៉ុណ្ណោះ

+កូនក្ដីខ្ញុំមានសាក្សី តែត្រូវតុលាការក្រោមមិនពិចារណាទេ

+ខ្ញុំបាននាំសាក្សី ៣នាក់ ខាងកូនក្ដីមកសាលាឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍ក៏មិនបានសួរដេញដោលទៀត ដូច្នេះឃើញថា វាជារឿងអយុត្តិធម៌ណាស់ សូមតុលាការកំពូល បង្វិលសំណុំរឿងនេះ ទៅសាលាឧទ្ធរណ៍វិញ ដើម្បីឱ្យចាត់របៀបស៊ើបអង្កេត លើសាក្សីកូនក្ដីខ្ញុំផង ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី លោក ស៊ុម ស៊ីថាន ជាមេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណីនាពេលសវនាការ ថា: ក្នុងរឿងនេះ :

+ភាគីខាងជនជាប់ចោទជាអ្នកផ្ដើម ដោយដើរជេរ ទេរិញទៅមកលើកូនក្ដីខ្ញុំ

+ការដែលចោទកូនក្ដីខ្ញុំថា ឱ្យមានទោសនោះ គឺគ្មានភស្ដុតាងណាច្បាស់លាស់ ដែលដាក់បន្ទុកលើកូនក្ដីខ្ញុំនោះទេ ។

+កូនក្ដីខ្ញុំមានស្នាមរយៈនៅនឹងក និងលើទ្រូង

+កូនក្ដីខ្ញុំបានដាច់ខ្សែកមួយកង់

+កូនក្ដីខ្ញុំមានកោសល្យវិច័យពេទ្យត្រឹមត្រូវ

+កូនក្ដីខ្ញុំមានសាក្សីដឹងឮ នៅពេលកើតហេតុដូចជា ប៉ូលិស មេឃុំ ពិសេស គឺសាក្សីរបស់ជនជាប់ចោទក៏ បានបញ្ជាក់ថា ព្រេស សាមាន មានស្នាមលើក និងទ្រូង ។

យោងទៅលើសាក្សី និង ភស្ដុតាង សូមតុលាការកំពូលតម្កល់ សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: គ្មានយោបល់បន្ថែមទេ ។

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ ឈ្មោះសាង ណាង ,សាង នី ,ស៊ុង ប៉េប ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីគូភាគី។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៧១ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះសាង ណាង

សាង នី .ស៊ីង ប៉េប ប្ដឹងពីសាលដីកាព្រហ្មទណ្ឌលេខ៣៣"គ" ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើចំណុចទាំងមូល ធ្វើឡើងក្នុងកំនត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

-យល់ឃើញថា កាលពីនៅសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ សាង នី .ស៊ីង ប៉េប .សាង ណាង បានស្នើសុំដល់មហាអយ្យការ អមសាលាឧទ្ធរណ៍ឱ្យធ្វើការ សាកសួរសាក្សីរបស់ខ្លួនចំនួន៣រូប តាមលិខិតចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០០ ហើយក៏ដូចនៅពេលសវនាការជាន់សាលាឧទ្ធរណ៍ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ ដែរ គឺជនជាប់ចោទនៅតែសំណូមពរដដែល តែសាលាឧទ្ធរណ៍ពុំបានលើកយកទៅពិចារណា និងសំរេចឡើយ ចំណុចនេះបានបំពានលើមាត្រា២០៩ ចំណុចទី៣ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣ ហើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីព្រហ្មទណ្ឌលេខ៣៣ "គ" ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី

១-ទទួលបណ្ដឹងសាទុក្ខលេខ៧១ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះសាង ណាង.សាង នី ស៊ីង ប៉េប ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៣៣ "គ" ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ របស់សាលឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៦៥ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅសាលា ឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។